**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...៦៨...សសរ.

# សេចក្តីសម្រេច

## ស្តីពី

## ការបំពេញបន្ថែមសមាជិកក្រុមជំនួយការនៃក្រុមការងារ ថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធី នយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងសេចក្តីណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជាលេខ០១ សណន ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៤ ស្តីពី តួនាទី ភារកិច្ច និង របៀបរបបការងារសម្រាប់ក្រុមការងារចុះបំពេញបេសកកម្មតាមមូលដ្ឋាន ដើម្បី ត្រួតពិនិត្យ និង គាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣របស់រាជរដ្ឋាភិបាលកម្ពុជា
- យោងសេចក្តីសម្រេចលេខ២៩ សសរ ចុះថ្ងៃទី៣០/០៣/២០១៥ របស់រាជរដ្ឋាភិបាល
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១ .-**

ត្រូវបានបំពេញបន្ថែមសមាជិកក្រុមជំនួយការនៃក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្ត កម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា ដែលមានសមាសភាពដូចខាងក្រោម ៖

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **អេង មង្គល** | អនុរដ្ឋលេខាធិការ ក្រសួង មហាផ្ទៃ | សមាជិក |
| ២-ឯកឧត្តម | **ឌី សុភផាន** | អនុរដ្ឋលេខាធិការ ក្រសួង មហាផ្ទៃ | សមាជិក |

| | | | |
|---|---|---|---|
| ៣-ឯកឧត្តម | **ឱម សំអ៊ើល** | អនុរដ្ឋលេខាធិការ ក្រសួង អភិវឌ្ឍន៍ជនបទ | សមាជិក |
| ៤-ឯកឧត្តម | **កៅ ល្អប្រពៃ** | អនុរដ្ឋលេខាធិការ ក្រសួង រ៉ែ និង ថាមពល | សមាជិក |
| ៥-ឯកឧត្តម | **កើត មៀច** | អនុរដ្ឋលេខាធិការ ក្រសួង សុខាភិបាល | សមាជិក |
| ៦-ឯកឧត្តម | **សៅវណ្ណ សិរីវុឌ្ឍ** | អនុរដ្ឋលេខាធិការ ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | សមាជិក |
| ៧-ឯកឧត្តម | **ម៉ៅ ឡាំង** | អនុរដ្ឋលេខាធិការ ក្រសួង សាធារណការនិង ដឹកជញ្ជូន | សមាជិក |
| ៨-លោកជំទាវ | **សួស រដ្ឋាវី** | អនុរដ្ឋលេខាធិការ ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ៩-ឯកឧត្តម | **ពេជ្រ វាសនា** | អគ្គលេខាធិការរង អាជ្ញាធរទន្លេសាប | សមាជិក |
| ១០-ឯកឧត្តម | **ម៉ែន ច័ន្ទសុខរិន** | អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាលកិច្ចការទូទៅ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច | សមាជិក |
| ១១-ឯកឧត្តម | **ចោង មូរ៉ាន់** | អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួង អប់រំយុវជន និង កីឡា | សមាជិក |
| ១២-ឯកឧត្តម | **សេង ថានី** | អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួង រៀបចំដែនដី នគរូបនីយកម្ម និង សំណង់ | សមាជិក |
| ១៣-ឯកឧត្តម | **គីម សុភ:** | នាយកខុទ្ទកាល័យ ក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១៤-ឯកឧត្តម | **អ៊ុំ សុថា** | អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាលកិច្ចការទូទៅ ក្រសួង ឧស្សាហកម្ម និង សិប្បកម្ម | សមាជិក |
| ១៥-ឯកឧត្តម | ឧត្តមសេនីយ៍ឯក **ស៊ុង ខាំចាន់តារ៉ុង** | ប្រធានក្រុមស្រាវជ្រាវជំនាញប្រវត្តិសាស្ត្រ កងទ័ព ក្រសួងការពារជាតិ | សមាជិក |

**ប្រការ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ២០១៥

ជ. នាយករដ្ឋមន្ត្រី

ឧបនាយករដ្ឋមន្ត្រី

**សម្តេចក្រឡាហោម ស ខេង**

កន្លែងទទួល

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី

-គ្រប់ក្រសួង-ស្ថាប័ន

-ប្រធានក្រុមការងារថ្នាក់ជាតិ ចុះរាជធានី ខេត្ត

-សាលារាជធានី ខេត្ត

-សាមីខ្លួនដូចមានចែងក្នុងប្រការ១

-ឯកសារ-កាលប្បវត្តិ